ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការធ្វើអនុបយោគ ប្ដូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ៩៥០ សជណ.ឧស ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៨៧៥ សជណ.ឧស ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ១៤១៤ លស.អរហ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងទេសចរណ៍
- ផែនទីកំណត់និយាមកាតំបន់អភិវឌ្ឍកំពតថ្មី ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត។

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវទីតាំងដីទំហំ ២៤៨ (ពីររយសែសិបប្រាំបី) ហិកតា ស្ថិតនៅតំបន់កំពតថ្មី ក្នុងភូមិជុំគ្រៀល ឃុំជុំគ្រៀល ស្រុកទឹកឈូ ខេត្តកំពត ដែលមានផែនទីកំណត់និយាមកាតំបន់ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ក្នុងគម្រោងតំបន់អភិវឌ្ឍកំពតថ្មី។

**មាត្រា២.-**

ផ្ទៃដីដែលត្រូវបានធ្វើអនុប្បយោគដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងទេសចរណ៍ដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១១កើតខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

ផែនទីបង្ហាញទីតាំងដីគម្រោង តំបន់អភិវឌ្ឍកំពតថ្មីរបស់ក្រសួងទេសចរណ៍ ស្ថិតនៅភូមិជុំគ្រៀល ឃុំជុំគ្រៀល ស្រុកទឹកឈូ ខេត្តកំពត




តារាងនិយាមកាតំបន់អភិវឌ្ឍកំពតថ្មី
Projection, UTM, Zone 48N
Datum, WGS 1984

| ID | E | N |
|---|---|---|
| 1 | 415223.531 | 1166085.148 |
| 2 | 415253.666 | 1166076.525 |
| 3 | 415317.061 | 1166054.382 |
| 4 | 415407.189 | 1166113.993 |
| 5 | 415496.095 | 1166191.785 |
| 6 | 415657.613 | 1166411.780 |
| 7 | 415890.891 | 1166670.734 |
| 8 | 416151.667 | 1166901.973 |
| 9 | 416394.603 | 1167075.910 |
| 10 | 416644.760 | 1167218.436 |
| 11 | 416895.174 | 1167308.728 |
| 12 | 417143.261 | 1167312.382 |
| 13 | 417330.904 | 1167270.697 |
| 14 | 417529.850 | 1167177.815 |
| 15 | 417753.054 | 1166986.097 |
| 16 | 417970.786 | 1167075.619 |
| 17 | 418112.137 | 1167264.697 |
| 18 | 418120.399 | 1167384.662 |
| 19 | 417976.231 | 1167675.485 |
| 20 | 416985.042 | 1168168.777 |
| 21 | 416341.790 | 1167999.147 |
| 22 | 415764.133 | 1168028.612 |
| 23 | 415621.892 | 1167929.753 |
| 24 | 415709.762 | 1167623.014 |
| 25 | 415657.930 | 1167257.605 |
| 26 | 415337.247 | 1166639.206 |
| 27 | 415203.036 | 1166210.391 |

លេខ : ...
បានឃើញនិងឯកភាព
ថ្ងៃ ពុធ ១២កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
កំពត ថ្ងៃទី ១៩ ខែ ១២ ឆ្នាំ២០១៨
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម
សំណង់ និងសុរិយោដីខេត្តកំពត

លេខ : ...
បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ ពុធ ១២កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ទឹកឈូ ថ្ងៃទី ១៩ ខែ ១២ ឆ្នាំ២០១៨
ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម
សំណង់ និងសុរិយោដីស្រុកទឹកឈូ

ថ្ងៃ ពុធ ១២កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ថ្ងៃទី ១៩ ខែ ១២ ឆ្នាំ២០១៨
មន្ត្រីវាស់វែង

សេង ពិសិដ្ឋ